**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**THE ARBITRATION COUNCIL**

លេខ និង ឈ្មោះសំណុំរឿង ៖ ០៣១/២០ - រូស៊ីង ហ្វាម៉ែន

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ លីវ សុវណ្ណា

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន រូស៊ីង ហ្វាម៉ែន**

អាសយដ្ឋាន ៖ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៣០ ៩០១ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក តាំង ម៉េង មេធាវី

២- លោក ជូ ចាន់ស័ក ប្រធានផ្នែកដោះស្រាយវិវាទការងារក្រុមហ៊ុន

៣- លោកស្រី ឡាក់ ដាក់មុន្នី ប្រធានផ្នែករដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន រូស៊ីង ហ្វាម៉ែន**

អាសយដ្ឋាន ៖ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៥៥ ៧៩២/ ០១២ ៨៨ ០០ ៣៩ ទូរសារ ៖ គ្មាន

តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោកស្រី យ៉ាង សុភ័ណ្ឌ ប្រធានសហព័ន្ធសហជីពកម្ពុជា(CATU)

២- លោកស្រី ពាញ គឿន មន្ត្រីសហព័ន្ធសហជីពកម្ពុជា

៣- លោក ជួន ជា ប្រធានសហជីព(មូលដ្ឋាន)

៤- លោក ឯក សារុន អនុប្រធានសហជីព(មូលដ្ឋាន)

| | |
|---|---|
| ៥- លោក សុខ គង់ | លេខាសហជីព |
| ៦- លោក កន សុច | តំណាងកម្មករ |
| ៧- លោកស្រី ឈូក សារ៉ាន | កម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុន នៅពេលបញ្ឈប់កម្មករនិយោជិតម្នាក់ៗ សុំឱ្យទូទាត់ប្រាក់បំណាច់ទៅតាមច្បាប់ ០៥ចំណុច តាមច្បាប់ស្តីពីការងារដោយសារតែមួយរយៈនេះ ក្រុមហ៊ុនទូទាត់ប្រាក់ឈ្នួលឱ្យ មិនត្រឹមត្រូវតាមច្បាប់ស្តីពីការងារ (មានកម្មករនិយោជិតចំនួន ០៥នាក់)។ ដោយឡែក ភាគីនិយោជក បានបញ្ជាក់ថា នៅពេលក្រុមហ៊ុនបញ្ឈប់កម្មករនិយោជិតណាម្នាក់ ក្រុមហ៊ុនបានទូទាត់ប្រាក់ឈ្នួល និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ ជូនពួកគាត់តាមច្បាប់ស្តីពីការងាររួចហើយ។

២- កម្មករនិយោជិតនៅតែទាមទារសុំឱ្យក្រុមហ៊ុនបញ្ឈប់ការរើសអើងប្រឆាំងសហជីពកម្ពុជា(CATU) ព្រោះថា៖ នៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២០ បានរើសអើង និងជ្រៀតជ្រែកការងារសហជីព ដោយព្រមានកម្មករឈ្មោះ កន សុច ដោយគ្រាន់តែកម្មករគេទូរស័ព្ទរកសហជីព ដើម្បីសួរនាំលក្ខខណ្ឌការងារប៉ុណ្ណោះ។

- នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ រដ្ឋបាលបានជ្រៀតជ្រែកការងារសហជីព ចាប់យកក្រដាសផ្តិតមេដៃរបស់សហជីពដែលសហជីពធ្វើការផ្តិតមេដៃកម្មករនៅម៉ោងសម្រាកការងារ។

- នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ក្រុមហ៊ុនប្រាប់ប្រធានក្រុមដើរប្រាប់កម្មករណាដែលបានផ្តិតមេដៃឱ្យសហជីពកម្ពុជា(CATU) ត្រូវដកស្នាមមេដៃចេញវិញ បើអត់ដកប្រយ័ត្នមានបញ្ហា។

- ក្រុមហ៊ុនមិនព្រមកាត់ប្រាក់ភាគទានសមាជិកសហជីពកម្ពុជា(CATU)ឱ្យមកសហជីព។ ដោយឡែក ភាគីនិយោជិកបានបញ្ជាក់ថា ក្រុមហ៊ុនពុំមានការរើសអើងសហជីពកម្ពុជា(CATU)នោះទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩(អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន លេខ៤៧៤ ក.ប/អក/វក ចុះថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៣ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃចន្ទ ៨កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ត្រូវនឹងថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

បញ្ហានីតិវិធី ៖

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន រ៉ូស៊ីង ហ្គាម៉ែន ស្នើសុំឱ្យជួយដោះស្រាយលក្ខខណ្ឌការងារចំនួន ២ចំណុច។ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ នាយកដ្ឋានវិវាទការងារ បានអញ្ជើញភាគីទាំងពីរមកចូលរួមដោះស្រាយវិវាទការងាររួម ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចវិវាទដែលមិនសះជាចំនួន ២ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន រ៉ូស៊ីង ហ្គាម៉ែន លេខ ៤៧៤ ក.ប/អក/វក ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ២ចំណុចនេះ នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោង ២ រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

នៅក្នុងសវនាការ ភាគីកម្មករនិយោជិតបានលើកឡើងថា ចំណុចវិវាទនៅក្នុងបណ្តឹងដើម ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ ដែលកម្មករនិយោជិតបានដាក់ទៅនាយកដ្ឋានវិវាទការងារ គឺមានចំនួន ៣ចំណុច ក្នុងនោះមានការស្នើសុំឱ្យក្រុមហ៊ុនទទួលយកតំណាងកម្មករ ថ្នាក់ដឹកនាំ សកម្មជន រួមទាំងសមាជិកសហជីពចូលបំរើការងារវិញធម្មតា ១. ឯក សារុន ២. សុខ គង់ ៣. កន សុច ៤. ឈូក រ៉ា ៥. នល់ នាន។ ដោយឡែក នៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារដែលបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវិវាទចំនួនតែ ២ចំណុចប៉ុណ្ណោះ ពោលគឺបាត់ការទាមទារដែលសុំឱ្យនិយោជកទទួលយកកម្មករនិយោជិតចូលធ្វើការងារវិញ ដែលជាការទាមទារចម្បងរបស់កម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ។ ករណីនេះ ភាគីកម្មករនិយោជិតបានស្នើសុំឱ្យអាជ្ញាកណ្តាលលើកយកចំណុចវិវាទដែលមាននៅក្នុងបណ្តឹងដើមទាំង ៣ចំណុច មកដោះស្រាយក្នុងសវនាការអាជ្ញាកណ្តាល បើមិនដូច្នោះ ភាគីកម្មករនិយោជិតនឹងមិនចូលរួមសវនាការទេ។ ករណីនេះដែរ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចពិចារណាការទាមទារលើចំណុចវិវាទមិនសះជាចំនួន ២ចំណុច ដែលនាយកដ្ឋានវិវាទការងារបញ្ជូនមកតែប៉ុណ្ណោះ។ ហេតុនេះ បន្ទាប់ពីការសាកសួរនៅក្នុងបន្ទប់សវនាការ ភាគីកម្មករនិយោជិតបានសម្រេចធ្វើពហិការមិនចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ពាក់ព័ន្ធនឹងចំណុចវិវាទដែលមិនសះជាចំនួន ២ចំណុច ដែលមាននៅក្នុងរបាយការណ៍មិនសះជានេះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់លោកនាយកក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន ផ្ទេរសិទ្ធិជូនលោកស្រី ... តាំង មេង លោក ជូ ចាន់ស័ក និងលោកស្រីឡាក់ ដារ៉ាមុន្នី ជាតំណាងមានមានសិទ្ធិជំនួសមុខក្រុមហ៊ុនក្នុងការ

ដោះស្រាយវិវាទការរួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃពុធ ៤កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ពស ២៥៦៤ ត្រូវនឹង ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន លេខ MOC-៣៥៦៤១៩២៦ ពណ.ចបព ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៩៩៧។

៣- ប័ណ្ណប៉ាតង់ឆ្នាំ២០១៩ ក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន លេខ PTL2019011722 អពដ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០ ដោយនាកដ្ឋានអធិការកិច្ចការងារ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ របស់អាណត្តិទាយកឈ្មោះ ជួន ជា, ឯក សារុន, សុខ គង់ និង កង សុច ជាតំណាងឱ្យកម្មករនិយោជិតនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន ប្រគល់សិទ្ធិជូន មេធាវី ហម ស៊ុនរិទ្ធិ ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០។

២- លិខិតរបស់មេធាវី ហម ស៊ុនរិទ្ធិ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីតំណាងដោយអាណត្តិ ឱ្យអាណត្តិទាយកឈ្មោះ ជួន ជា, ឯក សារុន, សុខ គង់, និង កង សុច ជាតំណាងឱ្យកម្មករនិយោជិតនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន លេខ ៤៧៤ ក.ប/អក/វក ចុះថ្ងៃពុធ ៧រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន រូស៊ីង ហ្គាម៉ែន លេខ ០០៦/២០ កប/អក/លបវ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៨៩ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១២រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៩០ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១២រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទដែលលាបែងនៅក្នុង របាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ

សារភាគីកម្មករនិយោជិត ដែលជាដើមបណ្តឹងបានធ្វើពហិការដោយដើរចេញមិនចូលរួមសវនាការរបស់ក្រុម-ប្រឹក្សាអាជ្ញាកណ្តាល។

**ហេតុផលនៃសេចក្តីសម្រេច ÷**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាល ឬត្រូវបញ្ចប់ដំណើរការអាជ្ញា-កណ្តាល ក្នុងករណីភាគីកម្មករនិយោជិតដែលជាដើមបណ្តឹងដើរចេញមិនព្រមចូលរួមសវនាការអាជ្ញាកណ្តាល?

ប្រការ ១៨ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ក្រុមអាជ្ញាកណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួននៅចំពោះមុខក្រុមអាជ្ញា-កណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត"*។

ប្រការ ២០ នៃប្រកាសដដែលនេះ ចែងថា ៖ *"...ភាគីវិវាទ...ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"*។

ប្រការ ២១ នៃប្រកាសដដែលនេះ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"*។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចែងថា ៖ *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

តាមរយៈប្រការ ១៨, ប្រការ ២០ និងប្រការ ២១ នៃប្រកាសលេខ ០៩៩ និងវិធាន ៤.៧ នៃឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ដែលបានលើកឡើងខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានកាតព្វកិច្ចអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់ នូវការអះអាងរបស់ខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងព័ត៌មានចាំបាច់ផ្សេងៗទៀត សម្រាប់ឱ្យក្រុម-ប្រឹក្សាអាជ្ញាកណ្តាលធ្វើការសម្រេចសេចក្តី។ ភាគីនៃវិវាទមានកាតព្វកិច្ចត្រូវចូលរួមរាល់កិច្ចប្រជុំទាំងអស់ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា "ពាក្យបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល" នៅក្នុងប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ ដែលបានលើកឡើងខាងលើនេះមានន័យថា ភាគីត្រូវតែមាន (១) វត្តមាននៅក្នុងសវនាការ និង (២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាលរហូតដល់សព្វគ្រប់ៗ ដំណើរការអាជ្ញាកណ្តាលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១៥/០៦-អាកឃីដ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា *"ការដើរចេញពីបន្ទប់សវនាការមុនដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចាប់ផ្តើម អាចចាត់ទុកថាជាការមិនបានមកបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល"។*

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានបង្ហាញខ្លួន និងមិនចូលរួមសវនាការ។ *(សូមមើលបន្ថែមសំណុំរឿងលេខ ១៦/០៧-ឡូទូសគី, លេខ ២៧/០៧-អ៊ឹម និង វ៉ា ៣, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១១/១១-ជូន តិចថាយល៍, លេខ ១៣១/១២-ម៉ាស្ទ័រ & ហ្វេង, លេខ ១០៨/១៣-អាត់តូ និងលេខ ៣៣២/ ១៤-ធី & ខេ ហ្គាមេន)*

កថាខណ្ឌទី ១ មាត្រា ៣១២ នៃច្បាប់ស្តីពីការងារ ១៩៩៧ បានចែងថា ៖ *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ..."។*

ប្រការ ៣៣ នៃប្រកាសលេខ ០៩៩ ចែងថា ៖ *"អំណាចរបស់ក្រុមអាជ្ញាកណ្តាលក្នុងការពិចារណាទៅលើវិវាទមួយ ត្រូវកំរិតត្រឹមតែបញ្ហាទាំងឡាយណាដែលមានក្នុងកំណត់ហេតុនៃការផ្សះផ្សាមិនបានសះជា ..."។*

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៧/០៧-អ៊ឹម និង វ៉ា ៣ *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាក់ថា មិនអាចដោះស្រាយវិវាទដទៃ ក្រៅពីវិវាទដែលមានបញ្ជាក់នៅក្នុងកំណត់ហេតុមិនសះជាបានទេ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការដោះស្រាយវិវាទ ដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនសះជាប៉ុណ្ណោះ"។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតមានវត្តមាននៅក្នុងសវនាការអាជ្ញាកណ្តាល។ បន្ទាប់ពីដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍, និងដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ ភាគីកម្មករនិយោជិតបានស្នើសុំឱ្យអាជ្ញាកណ្តាលលើកយកចំណុចវិវាទដែលមាននៅក្នុងបណ្តឹងដើមទាំង ៣ចំណុច មកធ្វើការដោះស្រាយក្នុងសវនាការអាជ្ញាកណ្តាល។ ករណីនេះដែរ យោងតាមមាត្រា ៣១២ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចពិចារណាការទាមទារលើចំណុចវិវាទមិនសះជាដែលមានចំនួន ២ចំណុច ដែលនាយកដ្ឋានវិវាទបញ្ជូនមកតែប៉ុណ្ណោះ។ ហេតុនេះ ភាគីកម្មករនិយោជិតបានសម្រេចចិត្តដើរចេញពីសវនាការអាជ្ញាកណ្តាល ដោយហេតុថា ចំណុចទាមទារចម្បងក្នុងបណ្តឹងដើមមិនត្រូវបានយកមកដោះស្រាយ។ ចំពោះការធ្វើពហិកាចូលរួមសវនាការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា ជាការបោះបង់បណ្តឹងរបស់ភាគីកម្មករនិយោជិត។ យោងតាមខ្លឹមសារប្រការ ១៨, ប្រការ ២០, ប្រការ ២១ នៃប្រកាសលេខ ០៩៩ និងវិធាន ៤.៧ នៃឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាល។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ០៣១/២០ រ៉ូស៊ីង ហ្គាម៉ែន នេះ។

**សម្រេច**

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ០៣១/២០-រ៉ូស៊ីង ហ្គាម៉ែន។

THE ARBITRATION COUNCIL

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុខ សុទ្ធី**

ហត្ថលេខា ៖ ----------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា ៖----------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ----------------------------------